ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០០៦៣ ព.ណ.ផ.ក.ឧម.ប្រក

# ប្រកាស
# ស្តីពី
# បែបបទនិងនីតិវិធីនៃការជ្រើសរើសសមាជិកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ដែលជាបុគ្គលឯករាជ្យ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនឹងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការជ្រើសរើសសមាជិកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា "គ.ប.ក." ដែលជាបុគ្គលឯករាជ្យ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់និងសមស្រប ដោយផ្អែកលើគោលការណ៍តម្លាភាព យុត្តិធម៌ និងសមធម៌។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង អាណត្តិបន្ទាប់ និងក្នុងករណីដែលមានមុខតំណែងនៅទំនេរ។

បែបបទនិងនីតិវិធីនៃការជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យនៅក្រោមបទប្បញ្ញត្តិនៃប្រកាសនេះមិនត្រូវយកមកអនុវត្ត ចំពោះសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យដែលត្រូវតែងតាំងសារជាថ្មីសម្រាប់អាណត្តិបន្ទាប់។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះមាននិយមន័យដូចខាងក្រោម៖

១. **អ្នកដាក់ពាក្យស្នើសុំ** សំដៅដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំធ្វើជាសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ។

២. **ពាក្យស្នើសុំ** សំដៅដល់ទម្រង់ពាក្យស្នើសុំសម្រាប់ជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យដែលត្រូវកំណត់ដោយគណៈកម្មការជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ។

៣. **ច្បាប់ស្តីពីការប្រកួតប្រជែង** សំដៅដល់ច្បាប់ស្តីពីការប្រកួតប្រជែង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១។

៤. **សមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យអាណត្តិដំបូង** សំដៅដល់សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ ដែលត្រូវបានជ្រើសរើសសម្រាប់អាណត្តិដំបូង។

៥. **សមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យអាណត្តិបន្ទាប់** សំដៅដល់សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ ដែលត្រូវបានជ្រើសរើសឬតែងតាំងសម្រាប់អាណត្តិបន្ទាប់ ។

៦. **គណៈកម្មការជ្រើសរើស** សំដៅដល់គណៈកម្មការជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យដូចមានកំណត់នៅក្នុងប្រកាសនេះ។

៧. **លេខាធិការដ្ឋាននៃគណៈកម្មការជ្រើសរើស** សំដៅដល់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "ក.ប.ប." ដែលមានតួនាទី និងភារកិច្ចផ្តល់កិច្ចគាំទ្រផ្នែករដ្ឋបាលនិងប្រតិបត្តិការចាំបាច់នានានៅក្នុងដំណើរការជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ។

៨. **បេក្ខជនដែលជាប់សម្រាំង** សំដៅដល់បុគ្គលដែលត្រូវបានជ្រើសរើសសម្រាប់នីតិវិធីជ្រើសរើសបន្ត។

# ជំពូកទី២
## គោលការណ៍នៃការជ្រើសរើសសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យ

**ប្រការ៤.-**

គ.ប.ក. ត្រូវមានសមាជិកដែលជាបុគ្គលឯករាជ្យចំនួន ៥(ប្រាំ)រូប មានសមាសភាពដូចខាងក្រោម៖

- អតីតចៅក្រម ១រូប
- បុគ្គលដែលមានចំណេះដឹងនិងបទពិសោធផ្នែកច្បាប់ ២រូប
- បុគ្គលដែលមានចំណេះដឹងនិងបទពិសោធផ្នែកសេដ្ឋកិច្ច ២រូប។

**ប្រការ៥.-**

សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យដែលជាអតីតចៅក្រម ត្រូវមានចំណេះដឹងនិងបទពិសោធនៅក្នុងវិជ្ជាជីវៈរបស់ខ្លួនដូចខាងក្រោម៖

- មានចំណេះដឹងក្នុងវិស័យច្បាប់ ឬគោលនយោបាយសាធារណៈពាក់ព័ន្ធនឹងការប្រកួតប្រជែង កិច្ចការពារអ្នកប្រើប្រាស់ ធុរកិច្ច និងវិស័យពាក់ព័ន្ធផ្សេងទៀត
- មានបទពិសោធក្នុងកិច្ចការតុលាការ ឬកិច្ចការច្បាប់ នៅក្នុងសាលាជម្រះក្តី សាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីវិសាមញ្ញណាមួយ នៅក្នុងក្រសួងឬស្ថាប័នណាមួយ។

សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យដែលមានចំណេះដឹងនិងបទពិសោធផ្នែកច្បាប់ ត្រូវមានចំណេះដឹងនិងបទពិសោធនៅក្នុងវិជ្ជាជីវៈរបស់ខ្លួនដូចខាងក្រោម៖

- មានចំណេះដឹងក្នុងវិស័យច្បាប់ ដោយមានជំនាញពាក់ព័ន្ធនឹងនីតិកិច្ចការប្រកួតប្រជែង នីតិកិច្ចការពារអ្នកប្រើប្រាស់ នីតិរដ្ឋបាល នីតិធុរកិច្ច នីតិកម្មសិទ្ធិបញ្ញា នីតិពាណិជ្ជកម្មអន្តរជាតិ ឬនីតិពាក់ព័ន្ធផ្សេងទៀត
- មានបទពិសោធក្នុងកិច្ចការតុលាការ ឬកិច្ចការច្បាប់ នៅក្នុងសាលាជម្រះក្តី សាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីវិសាមញ្ញណាមួយ នៅក្នុងក្រសួងឬស្ថាប័នណាមួយ ឬ
- មានបទពិសោធជាមេធាវី ទីប្រឹក្សាច្បាប់ ឬមន្ត្រីទទួលបន្ទុកផ្នែកច្បាប់ ពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នានៃធុរកិច្ច ការអនុវត្តតាមអនុលោមភាពនៃច្បាប់ ប្រតិបត្តិការធុរកិច្ច ឬកិច្ចការផ្សេងៗ ដែលស្ថិតនៅក្រោមនីតិកិច្ចការប្រកួតប្រជែង នីតិកិច្ចការពារអ្នកប្រើប្រាស់ នីតិធុរកិច្ច ឬនីតិពាក់ព័ន្ធនានា ឬ
- មានបទពិសោធនៅក្នុងសាកលវិទ្យាល័យ ឬស្ថាប័នសិក្សាស្រាវជ្រាវដែលមានកេរ្តិ៍ឈ្មោះក្នុងមុខតំណែងជាសាស្ត្រាចារ្យ គ្រូបង្រៀន ឬអ្នកស្រាវជ្រាវអំពីនីតិកិច្ចការប្រកួតប្រជែង នីតិកិច្ចការពារអ្នកប្រើប្រាស់ នីតិធុរកិច្ច ឬនីតិពាក់ព័ន្ធនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជាឬនៅបរទេស។

សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ ដែលមានចំណេះដឹងនិងបទពិសោធផ្នែកសេដ្ឋកិច្ច ត្រូវមានចំណេះដឹងនិងបទពិសោធនៅក្នុងវិជ្ជាជីវៈរបស់ខ្លួនដូចខាងក្រោម៖

- មានចំណេះដឹងក្នុងវិស័យសេដ្ឋកិច្ច ដោយមានជំនាញសេដ្ឋកិច្ចឧស្សាហកម្ម អង្គភាពឧស្សាហកម្ម (Industrial Organization) ពាណិជ្ជកម្មអន្តរជាតិ អេកូណូមេទ្រិក (Econometrics) គណិតសាស្ត្រសេដ្ឋកិច្ច (Mathematical Economics) វិធីសាស្ត្រសេដ្ឋកិច្ចបែបបរិមាណវិស័យ (Quantitative Economic Methods) នីតិសាស្ត្រនិងសេដ្ឋកិច្ច ឬជំនាញប្រហាក់ប្រហែល
- មានបទពិសោធក្នុងការវិភាគបញ្ហាម៉ាក្រូសេដ្ឋកិច្ច ដោយរួមបញ្ចូលនូវពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគ ការវាយតម្លៃ និងប៉ាន់ស្មានគម្រោង អង្គភាពឧស្សាហកម្ម សេដ្ឋកិច្ចឧស្សាហកម្ម ឬនីយ័តកម្មសេដ្ឋកិច្ច (Economic Regulation) ដោយរួមមានការវាយតម្លៃការប្រកួតប្រជែង ការប្រើប្រាស់បច្ចេកទេសសេដ្ឋកិច្ចបែបបរិមាណវិស័យនៅក្នុងស្ថាប័នរដ្ឋ វិស័យសាធារណៈ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល ឬបញ្ញត្តិករ ឬអង្គការក្នុងតំបន់ អង្គការអន្តរជាតិ ឬអង្គការពហុភាគីជាដើម ឬ

- មានបទពិសោធនៅក្នុងសាកលវិទ្យាល័យ ឬស្ថាប័នសិក្សាស្រាវជ្រាវដែលមានកេរ្តិ៍ឈ្មោះក្នុងមុខតំណែងជា សាស្ត្រាចារ្យ គ្រូបង្រៀន ឬអ្នកស្រាវជ្រាវ អំពីវិស័យម៉ាក្រូសេដ្ឋកិច្ច សេដ្ឋកិច្ចឧស្សាហកម្ម អង្គភាពឧស្សាហកម្ម ពាណិជ្ជកម្មអន្តរជាតិ អេកូណូមេទ្រិក គណិតសាស្ត្រសេដ្ឋកិច្ច វិធីសាស្ត្រសេដ្ឋកិច្ចបែបបរិមាណវិស័យ ឬមុខវិជ្ជាប្រហាក់ប្រហែល។

**ប្រការ៦.-**

សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុយ៉ាងតិច ៣៥ (សាមសិបប្រាំ)ឆ្នាំ
- មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ
- មានកិត្តិយសនៅក្នុងវិជ្ជាជីវៈរបស់ខ្លួន ជាមួយបទពិសោធការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ
- ត្រូវបានទទួលស្គាល់ថាមានអត្តចរិតល្អ កេរ្តិ៍ឈ្មោះល្អ ភាពស្មោះត្រង់ និងសុចរិតភាព
- មានបរិញ្ញាបត្រផ្នែកច្បាប់ ឬមានសញ្ញាបត្រកម្រិតលើសពីនេះពាក់ព័ន្ធនឹងផ្នែកច្បាប់ សម្រាប់សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យដែលមានចំណេះដឹងនិងបទពិសោធផ្នែកច្បាប់
- មានបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬមានសញ្ញាបត្រកម្រិតលើសពីនេះពាក់ព័ន្ធនឹងផ្នែកសេដ្ឋកិច្ច សម្រាប់សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យដែលមានចំណេះដឹងនិងបទពិសោធផ្នែកសេដ្ឋកិច្ច
- មានអតីតភាពជាចៅក្រម សម្រាប់សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យដែលជាអតីតចៅក្រម។

## ជំពូកទី៣
## នីតិវិធីជ្រើសរើសសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យ
### ផ្នែកទី១
### នីតិវិធីជ្រើសរើសសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង

**ប្រការ៧.-**

ត្រូវបង្កើតគណៈកម្មការជ្រើសរើសមួយ ដោយមានការចូលរួមពីសមាជិកមួយចំនួន ដែលត្រូវដឹកនាំនិងចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីបំពេញការកិច្ចរៀបចំនិងជ្រើសរើសអ្នកដាក់ពាក្យស្នើសុំដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់និងសមស្រប សម្រាប់ស្នើសុំធ្វើជាសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង។

គណៈកម្មការជ្រើសរើសដែលត្រូវបានបង្កើតឡើងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវវិនិច្ឆ័យដោយផ្អែកលើលក្ខខណ្ឌចំណេះដឹង បទពិសោធ និងលក្ខណសម្បត្តិដូចមានចែងក្នុងប្រការ៥ និងប្រការ៦ នៃប្រកាសនេះ។

**ប្រការ៨.-**

សមាសភាពគណៈកម្មការជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូងរួមមាន៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - សមាជិកមួយចំនួនតាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធានឬសមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋាន**ក.ប.ប.** | សមាជិកនិងជាលេខាធិការ |

គណៈកម្មការជ្រើសរើស ត្រូវបើកកិច្ចប្រជុំនៅពេលចាំបាច់ ដើម្បីពិចារណាទៅលើការដាក់ពាក្យស្នើសុំនិងធ្វើសេចក្តីសម្រេចដោយការបោះឆ្នោតជ្រើសរើសបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់និងសមស្រប ដើម្បីស្នើសុំជ្រើសតាំងជាសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ។

កូរ៉ុមសម្រាប់កិច្ចប្រជុំរបស់គណៈកម្មការជ្រើសរើសត្រូវមានវត្តមានលើសពីពាក់កណ្តាល នៃចំនួនសមាជិកទាំងអស់។

ក្នុងករណីប្រធានគណៈកម្មការជ្រើសរើសអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានឬសមាជិកណាមួយដឹកនាំប្រជុំជំនួសបាន។

ក្នុងករណីដែលកិច្ចប្រជុំរបស់គណៈកម្មការជ្រើសរើសត្រូវបានផ្អាកនិងមិនអាចដំណើរការបានដោយមូលហេតុមិនគ្រប់ចំនួនកូរ៉ុមម្តងរួចហើយ ប្រធានអង្គប្រជុំអាចដំណើរការកិច្ចប្រជុំបន្ទាប់បានដោយមិនគិតពីចំនួនកូរ៉ុមឡើយ។

គណៈកម្មការជ្រើសរើសត្រូវធ្វើសេចក្តីសម្រេចតាមមតិភាគច្រើននៃសមាជិកដែលមានវត្តមាន។ ក្នុងករណីសំលេងឆ្នោតស្មើគ្នា សំលេងរបស់ប្រធានអង្គប្រជុំមានឧត្តមានុភាព។

**ប្រការ៩.-**

គណៈកម្មការជ្រើសរើសត្រូវជូនដំណឹងជាសាធារណៈ តាមរយៈសារព័ត៌មានឬមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត ដើម្បីប្រកាសជូនដំណឹងដល់បុគ្គលដែលមានបំណងដាក់ពាក្យស្នើសុំធ្វើជាសមាជិក**គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ។

សេចក្តីជូនដំណឹងខាងលើ ត្រូវធ្វើឡើងជាសាធារណៈនៅក្នុងរយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ ជាប់ៗគ្នា និងត្រូវបញ្ជាក់លម្អិតអំពីលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ៥ និងប្រការ៦ នៃប្រកាសនេះ ព្រមទាំងបញ្ជាក់ពីកាលបរិច្ឆេទឈប់ទទួលពាក្យស្នើសុំ ពេលវេលា និងទីកន្លែងសម្រាប់ដាក់ពាក្យស្នើសុំ។

បន្ទាប់ពីផុតកាលបរិច្ឆេទទទួលពាក្យស្នើសុំដូចមានកំណត់នៅក្នុងសេចក្តីជូនដំណឹងខាងលើ គណៈកម្មការជ្រើសរើសត្រូវចាប់ផ្តើមត្រួតពិនិត្យ និងជ្រើសរើសបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់និងសមស្របក្នុងចំណោមអ្នកដាក់ពាក្យស្នើសុំ ដើម្បីធ្វើការវាយតម្លៃតាមរយៈការសម្ភាស ដូចមានចែងលម្អិតនៅក្នុងប្រការ១១ និងប្រការ១២ នៃប្រកាសនេះ។

**ប្រការ១០.-**

អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់នូវរាល់ព័ត៌មានដូចមានចែងក្នុងប្រការ៥ និងប្រការ៦ នៃប្រកាសនេះ ដោយប្រើប្រាស់ទម្រង់ពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះនិងត្រូវភ្ជាប់មកជាមួយនូវឯកសារគាំទ្រដែលតម្រូវក្នុងពាក្យស្នើសុំ ហើយត្រូវយកមកដាក់នៅលេខាធិការដ្ឋាននៃគណៈកម្មការជ្រើសរើស។

**ប្រការ១១.-**

លេខាធិការដ្ឋាននៃគណៈកម្មការជ្រើសរើស ត្រូវត្រួតពិនិត្យលើពាក្យស្នើសុំ និងរៀបចំបញ្ជីឈ្មោះអ្នកដាក់ពាក្យស្នើសុំដែលបានបំពេញគ្រប់លក្ខខណ្ឌ រួចបញ្ជូនមកគណៈកម្មការជ្រើសរើស។

បន្ទាប់ពីទទួលបានបញ្ជីឈ្មោះអ្នកដាក់ពាក្យស្នើសុំពីលេខាធិការដ្ឋាន គណៈកម្មការជ្រើសរើសត្រូវធ្វើការពិនិត្យនិងវាយតម្លៃលើព័ត៌មានរបស់អ្នកដាក់ពាក្យស្នើសុំ និងលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ៥ និងប្រការ៦ នៃប្រកាសនេះ ដើម្បីជ្រើសរើសបេក្ខជនសម្រាំងសម្រាប់នីតិវិធីជ្រើសរើសបន្តទៀត។

ដើម្បីធានានូវតម្លាភាពនៃការជ្រើសរើស គណៈកម្មការជ្រើសរើសត្រូវជូនដំណឹងជាសាធារណៈនូវបញ្ជីឈ្មោះបេក្ខជនដែលជាប់សម្រាំង។

**ប្រការ១២.-**

គណៈកម្មការជ្រើសរើស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបេក្ខជនដែលជាប់សម្រាំង ស្របតាមប្រការ១១ ដើម្បីធ្វើការសម្ភាស។ សេចក្តីជូនដំណឹងអំពីការសម្ភាសត្រូវបញ្ជាក់អំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរយៈពេលនៃការសម្ភាស។

បែបបទ និងនីតិវិធីនៃការសម្ភាស ការដាក់ពិន្ទុ និងដំណើរការនៃការសម្ភាសត្រូវកំណត់ដោយគណៈកម្មការជ្រើសរើស។

**ប្រការ១៣.-**

គណៈកម្មការជ្រើសរើសត្រូវផ្តល់ពិន្ទុដល់បេក្ខជនដែលជាប់សម្រាំងស្របតាមវិធានកំណត់ពិន្ទុដូចខាងក្រោម៖

១. ការដាក់ពិន្ទុ ដែលមានសរុបចំនួន ១០០ពិន្ទុ ត្រូវផ្តល់ឱ្យបេក្ខជនដែលជាប់សម្រាំងដោយសមាជិកគណៈកម្មការជ្រើសរើសនីមួយៗ ដោយបែងចែកជាពីរផ្នែកដូចខាងក្រោម៖

ក. មានចំណេះដឹង បទពិសោធ និងលក្ខណសម្បត្តិដូចមានចែងក្នុងប្រការ៥ និងប្រការ៦នៃប្រកាសនេះ ទទួលបានយ៉ាងច្រើនចំនួន ២០ពិន្ទុ នៃពិន្ទុសរុបចំនួន ១០០ពិន្ទុ តាមរយៈការពិនិត្យនិងវាយតម្លៃដោយហ្មត់ចត់ និងយុត្តិធម៌ ទៅលើពាក្យស្នើសុំនីមួយៗ។

ខ. មានការយល់ដឹង និងចក្ខុវិស័យនៅក្នុងវិស័យច្បាប់ និងបទប្បញ្ញត្តិស្តីពីការប្រកួតប្រជែង និងគោលនយោបាយសាធារណៈ ក៏ដូចជាវិស័យពាក់ព័ន្ធផ្សេងៗទៀត ដែលជាគុណប្រយោជន៍ដល់ការគ្រប់គ្រងការប្រកួតប្រជែង ទទួលបានយ៉ាងច្រើនចំនួន ៨០ពិន្ទុ នៃពិន្ទុសរុបចំនួន១០០ពិន្ទុ តាមរយៈការវាយតម្លៃដោយតម្លាភាព និងយុត្តិធម៌ នៅអំឡុងពេលធ្វើការសម្ភាស ដូចមានចែងក្នុងប្រការ១២ នៃប្រកាសនេះ។

២. គណៈកម្មការជ្រើសរើសត្រូវស្រង់ និងបូកពិន្ទុដែលកំណត់នៅក្នុងចំណុច ក និង ខ ខាងលើ ពីសមាជិកទាំងអស់នៃគណៈកម្មការជ្រើសរើស។ បញ្ជីពិន្ទុរបស់បេក្ខជនដែលជាប់សម្រាំងត្រូវរៀបតាមលំដាប់ពីបេក្ខជនដែលទទួលបានពិន្ទុខ្ពស់បំផុតនៅខាងលើ ហើយបេក្ខជនដែលទទួលបានពិន្ទុតិចជាងបន្តបន្ទាប់នៅខាងក្រោម។

**ប្រការ១៤.-**

គណៈកម្មការជ្រើសរើសត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីដំណើរការ និងលទ្ធផលនៃការជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ ដើម្បីធ្វើជាកំណត់ត្រាផ្ទៃក្នុង។

នៅក្នុងករណីដែលមិនអាចជ្រើសរើសបេក្ខជនគ្រប់ចំនួនសម្រាប់ការស្នើសុំតែងតាំងធ្វើជាសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ គណៈកម្មការជ្រើសរើសត្រូវពិចារណាបើកនីតិវិធីជ្រើសរើសជាថ្មីឡើងវិញ ស្របតាមបញ្ញត្តិនានាដែលមានចែងនៅក្នុងប្រកាសនេះ ដើម្បីជ្រើសរើសបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់និងសមស្របដើម្បីបង្គ្រប់ក្នុងតំណែងដែលនៅទំនេរ។

**ប្រការ១៥.-**

នៅក្នុងអំឡុងពេល ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ដំណើរការជ្រើសរើស គណៈកម្មការជ្រើសរើសត្រូវសម្រេចលើបញ្ជីឈ្មោះបេក្ខភាពសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ។

ក្រោយពីសម្រេចលើបញ្ជីឈ្មោះបេក្ខភាពសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ លេខាធិការដ្ឋាននៃគណៈកម្មការជ្រើសរើស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បេក្ខភាពដែលត្រូវបានជ្រើសរើស ដើម្បីស្នើសុំធ្វើជាសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ។

**ប្រការ១៦.-**

នៅពេលទទួលបានសមាសភាពតំណាងពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងទទួលបានបេក្ខភាពសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាប្រធាន **គ.ប.ក.** ត្រូវលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីធ្វើការតែងតាំងសមាសភាពនៃ **គ.ប.ក.**។

## ផ្នែកទី២
## នីតិវិធីជ្រើសរើសសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិបន្ទាប់ ឬក្នុងករណីដែលមានមុខតំណែងនៅទំនេរ

**ប្រការ១៧.-**

ត្រូវបង្កើតគណៈកម្មការជ្រើសរើសមួយ ដោយមានការចូលរួមពីសមាជិក **គ.ប.ក.** មួយចំនួន ដែលត្រូវដឹកនាំ និងចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាប្រធាន **គ.ប.ក.** ដើម្បីបំពេញភារកិច្ចរៀបចំនិងជ្រើសរើសអ្នកដាក់ពាក្យស្នើសុំដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់និងសមស្រប សម្រាប់ស្នើសុំធ្វើជាសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ ក្នុងករណីដូចខាងក្រោម៖

ក. នៅពេលអាណត្តិរបស់សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង ត្រូវបានបញ្ចប់ ឬ

ខ. នៅពេលមុខតំណែងសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យនៅទំនេរ។

**ប្រការ១៨.-**

សមាសភាពគណៈកម្មការជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិបន្ទាប់ឬនៅពេលដែលមានមុខតំណែងនៅទំនេររួមមាន៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាប្រធាន **គ.ប.ក.** | ប្រធាន |
| - សមាជិក **គ.ប.ក.** មួយចំនួន | អនុប្រធានឬសមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋាន **ក.ប.ប.** | សមាជិកនិងជាលេខាធិការ |

បញ្ញត្តិដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរសម្រាប់កិច្ចប្រជុំ កូរ៉ុម និងការធ្វើសេចក្តីសម្រេចរបស់គណៈកម្មការជ្រើសរើសសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិបន្ទាប់ឬនៅពេលដែលមានមុខតំណែងនៅទំនេរ។

**ប្រការ១៩.-**

ក្នុងករណីចាំបាច់ គណៈកម្មការជ្រើសរើសអាចតម្រូវឱ្យបេក្ខជនដែលជាប់សម្រាំង ចូលរួមក្នុងការប្រឡងវិញ្ញាសាសរសេរមុនពេលធ្វើការសម្ភាស។

ក្នុងករណីតម្រូវឱ្យមានការប្រឡងវិញ្ញាសាសរសេរ គណៈកម្មការជ្រើសរើសត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់បេក្ខជនដែលជាប់សម្រាំង ស្របតាមប្រការ១១ នៃប្រកាសនេះ ដើម្បីចូលរួមប្រឡងវិញ្ញាសាសរសេរ ដែលរៀបចំឡើងដោយគណៈកម្មការជ្រើសរើស ដើម្បីវាយតម្លៃទៅលើចំណេះដឹង ជំនាញ ការយល់ដឹង និងចក្ខុវិស័យនៅក្នុងការគ្រប់គ្រងការប្រកួតប្រជែង ឬទិដ្ឋភាពផ្សេងៗទៀតដែលជាប្រយោជន៍ដល់ការប្រតិបត្តិ និងអនុវត្តគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង។ សេចក្តីជូនដំណឹងអំពីការប្រឡងនេះត្រូវមានព័ត៌មានពាក់ព័ន្ធនឹងកាលបរិច្ឆេទ ពេលវេលា ទីកន្លែង រយៈពេល និងប្រធានបទនៃវិញ្ញាសាប្រឡងប្រសិនបើចាំបាច់។

បែបបទនិងនីតិវិធីនៃការប្រឡង ការដាក់ពិន្ទុ និងដំណើរការប្រឡងវិញ្ញាសាសរសេរ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការជ្រើសរើសស្របតាមគោលការណ៍ដូចខាងក្រោម៖

- វិញ្ញាសាសរសេរត្រូវមានប្រធានបទយ៉ាងហោចណាស់ចំនួនមួយអំពីគោលនយោបាយនិងច្បាប់ស្តីពីការប្រកួតប្រជែង
- វិញ្ញាសាសរសេរត្រូវធ្វើជាភាសាខ្មែរ
- ដំណើរការទាំងអស់នៃការប្រឡងវិញ្ញាសាសរសេរត្រូវមានតម្លាភាព យុត្តិធម៌ និងសមធម៌
- គណៈកម្មការជ្រើសរើសត្រូវរៀបចំតារាងកំណត់ពិន្ទុច្បាស់លាស់សម្រាប់ប្រធានបទវិញ្ញាសាសរសេរនីមួយៗ
- លទ្ធផលវិញ្ញាសាសរសេរត្រូវប្រកាសជាសាធារណៈ ហើយត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំ។

**ប្រការ២០.-**

ប្រការ៩ ប្រការ១០ ប្រការ១១ ប្រការ១២ ប្រការ១៣ ប្រការ១៤ ប្រការ១៥ និងប្រការ១៦ ត្រូវយកមកអនុវត្តដូចគ្នានៅក្នុងការជ្រើសរើសសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិបន្ទាប់ឬនៅពេលដែលមានមុខតំណែងនៅទំនេរ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២២.-**

សមាសភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ក.ប.ប. និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២២
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ០០៧៣ ពណ.អគសមប្រក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២៥
ស្តីពីបែបបទ និងនីតិវិធីនៃការជ្រើសរើសសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**គណៈកម្មការជ្រើសរើសសមាជិកគ.ប.ក.**
**ដែលជាបុគ្គលឯករាជ្យ**

## ពាក្យស្នើសុំធ្វើជាសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ

**ក. ប្រភេទសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ**

ចូរគូសសញ្ញា ✓ នៅក្នុងប្រអប់ ☐ ចំពោះប្រភេទសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យដែលអ្នកដាក់ពាក្យស្នើសុំជ្រើសរើស៖

☐ អតីតចៅក្រម

☐ បុគ្គលដែលមានចំណេះដឹងនិងបទពិសោធន៍ផ្នែកច្បាប់

☐ បុគ្គលដែលមានចំណេះដឹងនិងបទពិសោធន៍ផ្នែកសេដ្ឋកិច្ច

**ខ. ព័ត៌មានផ្ទាល់ខ្លួន**

ឈ្មោះ៖.................................................ឈ្មោះជាអក្សរឡាតាំង៖.........................................

ភេទ៖...........................ជនជាតិ៖...............................សញ្ជាតិ៖.........................................

ថ្ងៃខែឆ្នាំកំណើត៖.................................................. អាយុ៖...........................................

ទីកន្លែងកំណើត៖..........................................................................................................

.................................................................................................................................

អាសយដ្ឋានបច្ចុប្បន្ន៖.....................................................................................................

.................................................................................................................................

លេខទូរស័ព្ទ៖...............................................................................................................

អាសយដ្ឋានអេឡិចត្រូនិក(Email)៖.................................................................................

មុខរបរបច្ចុប្បន្ន៖.........................................អង្គភាព៖....................................................

អាសយដ្ឋានអង្គភាព៖......................................................................................................

## គ. កម្រិតវប្បធម៌ និងប្រវត្តិនៃការសិក្សា

- ពីឆ្នាំ...........ទៅឆ្នាំ........................ទទួលបានសញ្ញាបត្រ.............................................
ពី.................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................ទទួលបានសញ្ញាបត្រ.............................................
ពី.................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................ទទួលបានសញ្ញាបត្រ.............................................
ពី.................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................ទទួលបានសញ្ញាបត្រ.............................................
ពី.................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................ទទួលបានសញ្ញាបត្រ.............................................
ពី.................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................ទទួលបានសញ្ញាបត្រ.............................................
ពី.................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................ទទួលបានសញ្ញាបត្រ.............................................
ពី.................................................................................................................។

## ឃ. បទពិសោធន៍វិជ្ជាជីវៈ

- ពីឆ្នាំ...........ទៅឆ្នាំ........................បានធ្វើការជា.......................................................
នៅអង្គភាព..................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................បានធ្វើការជា.......................................................
នៅអង្គភាព..................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................បានធ្វើការជា.......................................................
នៅអង្គភាព..................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................បានធ្វើការជា.......................................................
នៅអង្គភាព..................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................បានធ្វើការជា.......................................................
នៅអង្គភាព..................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................បានធ្វើការជា.......................................................
នៅអង្គភាព..................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ........................បានធ្វើការជា.......................................................
នៅអង្គភាព..................................................................................................។

| ខ. ការប្រកាស/ការអះអាង |
| --- |
| ១. ខ្ញុំសូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានដែលបានបំពេញនៅក្នុងពាក្យស្នើសុំនេះនិងឯកសារភ្ជាប់ ពិតជាត្រឹមត្រូវប្រាកដដូចការអះអាងមែន។<br>២.ក្នុងករណីដែលត្រូវបានជ្រើសរើសជាសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ ខ្ញុំសុខចិត្តទទួល និងអនុវត្ត តួនាទី និងការងារជាសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ ដូចដែលមានកំណត់ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។<br>ថ្ងៃ....................ខែ....................ឆ្នាំ.......................... ព.ស.....................<br>ធ្វើនៅ........................ថ្ងៃទី.............ខែ..................ឆ្នាំ........................<br>ហត្ថលេខា<br>ឈ្មោះ៖................................ |

__ចំណាំ៖__ សូមភ្ជាប់មកជាមួយពាក្យស្នើសុំនេះផងដែរនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

| | | |
| --- | --- | --- |
| ១. | រូបថត ៤ x ៦ | ៣ សន្លឹក |
| ២. | ប្រវត្តិរូបសង្ខេប | ១ ច្បាប់ |
| ៣. | លិខិតថ្កោលទោស | ១ ច្បាប់ |
| ៤. | អត្តសញ្ញាណបណ្ណ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ(ថតចម្លង) | ១ ច្បាប់ |
| ៥. | លិខិតអនុសាសន៍ | ១ ច្បាប់ |
| ៦. | លិខិតបញ្ជាក់ទីលំនៅ | ១ ច្បាប់ |

៧. ឯកសារដែលជាភស្តុតាងបញ្ជាក់អំពីចំណេះដឹង និងបទពិសោធន៍ការងារ

៨. លិខិតពិពណ៌នាអំពីគោលបំណង ការបង្ហាញពីចំណេះដឹង សមត្ថភាព ជំនាញ និងបទពិសោធន៍ដែលសមស្របគ្រប់គ្រាន់សម្រាប់បំពេញមុខងារជាសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ ព្រមទាំងការយល់ដឹង និងចក្ខុវិស័យអំពីគោលនយោបាយក្នុងការប្រកួតប្រជែង កិច្ចការពារអ្នកប្រើប្រាស់ និង វិស័យពាក់ព័ន្ធរបស់ខ្លួន មិនលើសពី១០ទំព័រ។

ក្រសួងពាណិជ្ជកម្ម